**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
លេខៈ ០០៣/១៧ ... ពបហ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

នៅថ្ងៃសុក្រ ៥កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង៨ និង៣០នាទីព្រឹក នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង៖

**១- សេចក្តីព្រាងកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងឱនភាពដីឆ្នាំ ២០១៧-២០២៦ ។**

**២- សេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ ។**

**៣- បញ្ហាផ្សេងៗ៖** សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រីដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិបញ្ញត្តិលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សេវាកម្មក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា។

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសម្រេចអនុម័ត៖

**១- សេចក្តីព្រាងកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងឱនភាពដីឆ្នាំ ២០១៧-២០២៦ ។**

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យកសេចក្តីព្រាងកម្មវិធីសកម្មភាពជាតិនេះត្រឡប់ទៅកែសម្រួលឡើងវិញអោយបានពេញលេញ ដើម្បីអោយស្របទៅតាមសក្តានុពលដីកសិកម្មដែលមាន និងតម្រូវការអភិវឌ្ឍជាក់ស្តែងរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងវិស័យកសិកម្ម។

**២- សេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥**

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ត្រូវបានអនុម័ត ដោយគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥ និងត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនា**...

**បតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។** គោលនយោបាយនេះ គឺជាមគ្គុទ្ទេសក៍ផងដែរដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។ ចក្ខុវិស័យនៃគោលនយោបាយនេះ គឺជំរុញ កែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ ដោយខិតខំសម្រេចគោលដៅបីសំខាន់ គឺទី១-បង្កើនចំណែកនៃវិស័យឧស្សាហកម្ម ជាពិសេសវិស័យកម្មន្តសាល ក្នុងផលិតផលក្នុងស្រុកសរុប, ទី២-ជំរុញពិពិធកម្មមុខទំនិញនាំចេញក្រៅពីសម្លៀកបំពាក់ និងការនាំចេញកសិផលកែច្នៃ, និងទី៣- គាំទ្រដល់សហគ្រាសធុនតូច និងមធ្យម។ ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលដៅខាងលើនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រគន្លឹះបួន៖ ទី១-ការទាក់ទាញ និងទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងវិនិយោគឯកជនក្នុងស្រុក ទី២- ការអភិវឌ្ឍ និងធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម, ទី៣- ការកែលម្អបរិស្ថាននិយ័តកម្មដើម្បីពង្រឹងភាពប្រកួតប្រជែង និងទី៤-ការសម្របសម្រួលគោលនយោបាយគាំទ្រ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(ក.អ.ក) ក្នុងនាមជាស្ថាប័នដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ បានរៀបចំ និងដឹកនាំកិច្ចប្រជុំអន្តរក្រសួងជាច្រើនលើក ហើយអង្គប្រជុំបានសម្រេចដាក់ចេញនូវវិធានការជាច្រើនរួមទាំងការរៀបចំយន្តការផ្ទៃក្នុងរបស់ក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសមត្ថកិច្ចពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម, ការរៀបចំផែនការសកម្មភាពការងារ និងថវិកា, ការកំណត់ការងារដែលត្រូវធ្វើចំពោះមុខដែលអាចទទួលបាននូវផ្លែផ្កាឆាប់រហ័សទាំងផ្នែកសេដ្ឋកិច្ច និងសង្គម (Low Hanging Fruits) ដូចជាការជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម, ការជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការជំរុញការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស និងការជំរុញការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក។

តាមការពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ នាពេលកន្លងមក បានបង្ហាញឱ្យឃើញថា ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកំពុងស្ថិតនៅក្នុងទិសដៅត្រឹមត្រូវ និងអាចឈានទៅសម្រេចគោលដៅបានកំណត់នៅឆ្នាំ២០២៥។ ក្នុងន័យនេះ ការបន្តកិច្ចខិតខំប្រឹងប្រែងប្រកបដោយការទទួលខុសត្រូវខ្ពស់ និងកិច្ចសហការដ៏ល្អ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ និងការប្រើប្រាស់នូវធនធានសរុបមធ្យោបាយសរុប ក្រោមការដឹកនាំសម្របសម្រួលដ៏មានប្រសិទ្ធភាព គឺជាកត្តាគន្លឹះនៃការធានាជោគជ័យលើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនេះ។

**៣- បញ្ហាផ្សេងៗ៖** អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានអនុម័តបញ្ជូនទៅសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិនូវកិច្ចព្រមព្រៀងពាណិជ្ជកម្ម សេវាកម្មក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥៖

- ក្រើនរំលឹកដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជូនសាច់ប្រាក់ទៅឱ្យបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) សម្រាប់ការអនុវត្តការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដល់កម្មការិនី មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ ដែលឆ្លងទន្លេ ចាប់ពីម៉ោងសូន្យ ខែមករា ឆ្នាំ២០១៨។
- ប្រកាសក្រុមការងារដើម្បីរៀបចំបង្កើតធនាគារមួយនៅពេលឆាប់ៗខាងមុខនេះដើម្បីគាំទ្រដល់សហគ្រាស ធុនតូច និងមធ្យម ដើម្បីរួមចំណែកក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ ឱ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត។
- ណែនាំ និងជម្រុញថ្នាក់ដឹកនាំ ក្រសួងស្ថាប័នថ្នាក់ជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិដាច់ខាតបន្ត និងខិតខំអនុវត្តកម្មវិធីកំណែទម្រង់ នៅចុងអាណត្តិទី៥ នៃរដ្ឋសភារបស់រាជរដ្ឋាភិបាលតាមរយៈទិសស្លោក«ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល» ឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យថែមទៀត។
- ថ្លែងអំណរគុណ កោតសរសើរ ដល់មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទដែលបានខិតខំបំពេញការងារ ដើម្បីសុខ សន្តិភាព និងការអភិវឌ្ឍប្រទេសជាតិ អស់រយៈពេលពេញមួយឆ្នាំ២០១៧ និងជូនពរសុខភាពល្អ សិរីសួស្តី សុខកមង្គលក្នុងគ្រួសារក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល ២០១៨ ខាងមុខនេះ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង ១១ និង៥៥ នាទី ១៧

ថ្ងៃសុក្រ ០៥ កើត ខែបុស្ស ឆ្នាំ រកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃសុក្រ ទី ២២ ខែធ្នូ ឆ្នាំ ២០១៧